# នីតិអន្តរជាតិសាធារណៈ
# PUBLIC INTERNATIONAL LAW

## មេរៀនទី ៨

LECTURE 8

## រដ្ឋ ( ធាតុផ្សំនៃរដ្ឋ )

STATE (ELEMENTS OF STATE)

# មាតិកា

- កម្មវត្ថុនៃមេរៀន
- ផ្នែកទី១ សេចក្តីផ្តើម
- ផ្នែកទី២ ប្រជាជន
  - សញ្ញាណទូទៅ
- ផ្នែកទី៣ រដ្ឋាភិបាល
  - សញ្ញាណទូទៅ
  - ធាតុផ្សំនៃរដ្ឋាភិបាល
- ផ្នែកទី៤ ដែនដីរដ្ឋ
  - សញ្ញាណទូទៅ
  - សមាសភាពដែនដី

# កម្មវត្ថុនៃមេរៀន

មេរៀនស្តីពីរដ្ឋ (ធាតុផ្សំនៃរដ្ឋ) មានគោលបំណងឲ្យអ្នកសិក្សាបានស្វែងយល់ពី៖

- ការកកើតនៃរដ្ឋ?
- តើរដ្ឋត្រូវមានធាតុផ្សំអ្វី?
- តើធាតុផ្សំទាំងនោះមានអ្វីខ្លះ?
- សារៈសំខាន់នៃធាតុផ្សំនីមួយៗរបស់រដ្ឋ

# ផ្នែកទី១ សេចក្តីផ្តើម

រដ្ឋ គឺជាតួអង្គមួយនៃនីតិអន្តរជាតិសាធារណៈ ដែលត្រូវកើតឡើយដោយមានធាតុផ្សំរបស់ខ្លួនជាក់លាក់ ហើយក៏ជាតួអង្គតែមួយគត់ដែលមានអធិបតេយ្យ។ ដូចអ្នកសិក្សាបានដឹងហើយថា រដ្ឋអាចកើតឡើងក្នុងទម្រង់ជាច្រើនផ្សេងៗពីគ្នា ប៉ុន្តែអ្វីដែលយើងនឹងធ្វើការសិក្សានៅក្នុងមេរៀនេះ គឺធ្វើការសិក្សាទៅលើធាតុផ្សំតាមច្បាប់អន្តរជាតិ។

# ផ្នែកទី១ សេចក្តីផ្តើម

តាមច្បាប់អន្តរជាតិ រដ្ឋត្រូវមានធាតុផ្សំចំនួនបីសំខាន់ៗ ដែលរួមមាន៖ ប្រជាជន រដ្ឋាភិបាល (អ្នកដឹកនាំ ឬ អំណាចគ្រប់គ្រង) និងទឹកដី (ដែនដី)។ នៅក្នុងចំណោមធាតុផ្សំទាំងបីនេះ ប្រសិនបើគ្មានធាតុផ្សំណាមួយនោះទេ អត្ថិភាពរបស់រដ្ឋ គឺពុំមាននោះឡើយ។

# ផ្នែកទី១ សេចក្តីផ្តើម

ដូច្នេះ រដ្ឋនីមួយត្រូវគោរពនូវធាតុផ្សំដែលជាលក្ខខណ្ឌចាំបាច់មិនអាចខ្វះបាន គឺថាត្រូវមានប្រជាជនរបស់ខ្លួនមួយជាក់លាក់ ត្រូវមានរដ្ឋាភិបាលមួយដែលជាអង្គការចាត់តាំងនយោបាយ និងតំណាងឲ្យរដ្ឋក្នុងការធ្វើការគ្រប់គ្រង និងទំនាក់ទំនងទៅខាងក្រៅ ចុងក្រោយត្រូវមានទឹកដីមួយរបស់ខ្លួនពិតប្រាកដ។

# ផ្នែកទី១ សេចក្តីផ្តើម

នៅក្នុងមេរៀនទី៨ ស្តីពីរដ្ឋ (ធាតុផ្សំនៃរដ្ឋ)នេះ យើងនឹងធ្វើការសិក្សាទៅលើធាតុផ្សំចំនួនពីរ គឺប្រជាជន និងរដ្ឋាភិបាល ហើយចំណែកឯធាតុផ្សំដែលជាទឹកដី យើងនឹងធ្វើការសិក្សាលម្អិតនៅក្នុងមេរៀនទី៩ ស្តីពីរដ្ឋ (ដែនដីនៃរដ្ឋ)។

# ផ្នែកទី២ ប្រជាជន

- សញ្ញាណទូទៅ

ពាក្យថាប្រជាជន ឬ ប្រជាពលរដ្ឋ ត្រូវបានគេប្រើជាទូទៅ ប៉ុន្តែវានៅមានការភាន់ច្រឡំនៅក្នុងការប្រើប្រាស់ពាក្យទាំងពីរនេះ។ មានអ្នកសិក្សាមួយចំនួនបានលើកឡើងថា ពាក្យទាំងពីរនេះមានន័យដូចគ្នា ប៉ុន្តែអ្នកសិក្សាមួយចំនួនទៀតបានលើកឡើងថាពាក្យទាំងពីរនេះ មានន័យមិនដូចគ្នាទេ។

# ផ្នែកទី២ ប្រជាជន

- សញ្ញាណទូទៅ

ពាក្យថាប្រជាជន ឬ ប្រជាពលរដ្ឋ តាមន័យទូទៅគឺពុំមានអ្វីខុសគ្នានោះឡើយ។ ទស្សនវិទូបារាំងបានលើកឡើងថា ពាក្យទាំងពីរនេះ គឺពុំមានអ្វីខុសគ្នានោះឡើយ ដោយគេអាចប្រើពាក្យមួយណាក៏បានដែរ។

# ផ្នែកទី២ ប្រជាជន

- សញ្ញាណទូទៅ

ប្រជាជន ឬ ប្រជាពលរដ្ឋ តាមនៅទូទៅគឺសំដៅគ្រប់ជនទាំងឡាយណា ដែលកំពុងស្ថិតនៅក្រោមការគ្រប់គ្រងរបស់របស់រដ្ឋណាមួយ។ ពាក្យថាគ្រប់ជនទាំងឡាយនៅទីនេះ គឺសំដៅដល់ជនដែលមានចំណងបុគ្គលភាពគតិយុត្ត និងជនដែលពុំមានបុគ្គលភាពគតិយុត្ត។

# ផ្នែកទី២ ប្រជាជន

- សញ្ញាណទូទៅ

ជនដែលមានចំណងបុគ្គលភាពគតិយុត្ត គឺជាជនដែលមានសញ្ជាតិរបស់រដ្ឋនោះ បើទោះបីជាការទទួលបានសញ្ជាតិរបស់គាត់តាមមធ្យោបាយផ្សេងគ្នាក៏ដោយ។ ក្នុងករណីមួយចំនួនបុគ្គលអាចទទួលបានសញ្ជាតិតាមរយៈទីកន្លែងកំណើត និងករណីមួយចំនួនទៀត គេអាចទទួលបានសញ្ជាតិតាមរយៈសាច់ឈាម ជាអាទិ៍។

# ផ្នែកទី២ ប្រជាជន

- សញ្ញាណទូទៅ

សម្រាប់ជនដែលពុំមានបុគ្គលភាពគតិយុត្ត គឺសំដៅដល់ជនដែលពុំមានសញ្ជាតិរបស់រដ្ឋដែលខ្លួនកំពុងស្ថិតនៅ។ ជនដែលពុំមានសញ្ជាតិ និយាយដោយសាមញ្ញយើងសំដៅដល់ជនបរទេស ហើយដែលអាចជាជនបរទេសស្របច្បាប់ ឬជនបរទេសមិនស្របច្បាប់។

# ផ្នែកទី២ ប្រជាជន

- សញ្ញាណទូទៅ

ក្នុងក្របខណ្ឌនៃនីតិអន្តរជាតិសាធារណៈ ប្រជាជន ឬ ប្រជាពលរដ្ឋក្នុងន័យជាធាតុផ្សំរបស់រដ្ឋ គឺជាជនទាំឡាយណាដែលមានចំណងបុគ្គលភាពគតិយុត្ត គឺមានសញ្ជាតិរបស់រដ្ឋនោះ ទើបជាធាតុផ្សំដ៏ពិតប្រាកដនៃរដ្ឋ។

# ផ្នែកទី២ ប្រជាជន

- សញ្ញាណទូទៅ

រដ្ឋមួយពិតជាពុំមានអត្ថិភាពទេ ប្រសិនបើពុំមានប្រជាជនរបស់ខ្លួនពិតប្រាកដ។ ក្នុងករណីមានការធ្វើចរភាព ឬមានការផ្លាស់ទីនៃប្រជាជន ក៏ពុំប៉ះពាល់ដល់អត្តភាពរបស់រដ្ឋដែរ ឲ្យតែរដ្ឋនោះអាចរក្សាទុកចំនួនប្រជាជនណាមួយពិតប្រាកដ។

# ផ្នែកទី២ ប្រជាជន

- សញ្ញាណទូទៅ

ច្បាប់អន្តរជាតិ ពុំបានកំណត់ទេថា រដ្ឋមួយដើម្បីអាចមានអត្ថិភាពបាន ត្រូវមានប្រជាជនចំនួនប៉ុន្មាននោះឡើយ។ ប៉ុន្តែប្រសិនបើប្រជាជនមានចំនួនតិចពេក ក៏អាចធ្វើឲ្យរដ្ឋនោះជួបនូវផលវិបាកផងដែរ ព្រោះពុំមានធនធានមនុស្សគ្រប់គ្រាន់សម្រាប់ដំណើការសេវាសាធារណៈរបស់រដ្ឋខ្លួន។

# ផ្នែកទី៣ រដ្ឋាភិបាល

- សញ្ញាណទូទៅ

ប្រសិនបើរដ្ឋមានតែប្រជាជន គឺពុំទាន់គ្រប់គ្រាន់ឡើយ ដាច់ខាតត្រូវតែមានអង្គការចាត់តាំង ឬ អ្នកដឹកនាំពិតប្រាកដមួយ ដែលជាទូទៅគេហៅអង្គការចាត់តាំង ឬ អ្នកដឹកនាំនោះថា រដ្ឋាភិបាល។

# ផ្នែកទី៣ រដ្ឋាភិបាល

- សញ្ញាណទូទៅ

រដ្ឋាភិបាល គឺជានីតិបុគ្គល ដែលត្រូវបានបង្កើតឡើងដោយរូបវន្តបុគ្គលមួយក្រុម ដែលមាននិន្នាការនយោបាយដូចគ្នា ឬ ប្រហាក់ប្រហែលគ្នា ហើយដែលរដ្ឋាភិបាលនោះ មានសិទ្ធិអំណាចក្នុងការធ្វើទំនាក់ទំនងជាមួយរដ្ឋដ៏ទៃទៀត។

# ផ្នែកទី៣ រដ្ឋាភិបាល

- សញ្ញាណទូទៅ

រដ្ឋាភិបាល នៅទីនេះមិនសំដៅទៅតែអំណាចរបស់ស្ថាប័ននីតិប្រតិបត្តិនោះទេ គឺត្រូវកើតឡើងដោយធាតុផ្សំ ឬ ក៏ត្រូវពូនផ្តុំនូវអំណាចចំនួនបីគឺ អំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ។

# ផ្នែកទី៣ រដ្ឋាភិបាល

- សញ្ញាណទូទៅ

រដ្ឋាភិបាល មានសមត្ថភាព និងស្វ័យភាពគ្រប់គ្រាន់ក្នុងការជ្រើសរើសនូវប្រព័ន្ធគ្រប់គ្រងរដ្ឋរបស់ខ្លួន ដោយឆន្ទៈស្វ័យសម្រេចនូវប្រព័ន្ធនយោបាយ សេដ្ឋកិច្ច សង្គម វប្បធម៌ អប់រំ សិក្សាធិការ ជាអាទ៍។

# ផ្នែកទី៣ រដ្ឋាភិបាល

- ធាតុផ្សំនៃរដ្ឋាភិបាល

ដូចបានបង្ហាញពីខាងដើម រដ្ឋាភិបាលមួយត្រូវកើតចេញពីស្ថាប័ននៃអំណាចចំនួនបីរួមមាន ស្ថាប័នអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ អំណាចតុលាការ និងបូករួមជាមួយនិងរដ្ឋបាលសាធារណៈផងដែរ។

# ផ្នែកទី៣ រដ្ឋាភិបាល

- ធាតុផ្សំនៃរដ្ឋាភិបាល

អំណាចនីតិបញ្ញត្តិ: គឺជាស្ថាប័នមានអំណាចក្នុងការរៀបចំតាក់តែងច្បាប់សម្រាប់ការដំណើការ និងការប្រព្រឹត្តទៅនៃបណ្តាលរចនាសម្ព័ន្ធគ្រប់គ្រងដទៃទៀត។ ជាធម្មតា ស្ថាប័នអំណាចនីតិបញ្ញត្តិ ជាស្ថាប័ននអំណាចកំពូលរបស់រដ្ឋ។

# ផ្នែកទី៣ រដ្ឋាភិបាល

- ធាតុផ្សំនៃរដ្ឋាភិបាល

អំណាចនីតិបញ្ញត្តិ: ស្ថាប័ននេះមិនត្រឹមមានអំណាចក្នុងការបង្កើតនូវបទដ្ឋាន ឬ ច្បាប់ផ្ទៃក្នុងនោះឡើយ វាក៏នូវមានអំណាចក្នុងអនុម័តទទួលយក ឬ មិនទទួលយកនូវបទដ្ឋានអន្តរជាតិផងដែរ។ សូមកត់សំគាល់ថា ច្បាប់ដែលរៀបចំដោយស្ថាប័ននីតិបញ្ញត្ត គេហៅថាសេចក្តីស្នើច្បាប់។

# ផ្នែកទី៣ រដ្ឋាភិបាល

- ធាតុផ្សំនៃរដ្ឋាភិបាល

អំណាចនីតិប្រតិបត្តិ: គេអាចហៅអំណាចនីតិប្រតិបត្តិថាជាស្ថាប័ននីតិប្រតិបត្តិ។ ស្ថាប័ននេះ គឺជាក្បាលម៉ាស៊ីននៃការប្រតិបត្តិ នូវបទដ្ឋានទាំងឡាយដែលត្រូវបានអនុម័តដោយស្ថាប័ននីតិបញ្ញត្តិ។

# ផ្នែកទី៣ រដ្ឋាភិបាល

- ធាតុផ្សំនៃរដ្ឋាភិបាល

អំណាចនីតិប្រតិបត្តិ: សូមបញ្ជាក់ថា អំណាចនីតិប្រតិបត្តិ ឬស្ថាប័ននីតិប្រតិបត្តិ ក៏មានអំណាចក្នុងរៀបចំសេចក្តីព្រាងច្បាប់សម្រាប់គ្រប់គ្រង និងថែរក្សានូវសណ្តាប់ធ្នាប់នៅក្នុងប្រទេសរបស់ខ្លួនផងដែរ មានដូចជា ច្បាប់ អនុក្រឹត សេចក្តីណែនាំ ប្រកាស ជាអាទិ៍។

# ផ្នែកទី៣ រដ្ឋាភិបាល

- ធាតុផ្សំនៃរដ្ឋាភិបាល

តាមការសង្កេតជាក់ស្តែង ក្នុងករណីព្រះរាជាណាចក្រកម្ពុជា ច្បាប់ដែលត្រូវបានអនុម័តដាក់ឲ្យប្រើភាគច្រើន ត្រូវបាន រៀបចំព្រាងដោយស្ថាប័ននីតិប្រតិបត្តិ។ សូមបញ្ជាក់ថា ច្បាប់ដែលត្រូវបានរៀបចំដោយស្ថាប័ននីតិប្រតិបត្តិ គេហៅថាសេចក្តីស្នើច្បាប់។

# ផ្នែកទី៣ រដ្ឋាភិបាល

<u>កំណត់សម្គាល់:</u>

សូមចង់ចាំថា រដ្ឋាភិបាលពុំមាននិរន្តរភាពទេ គឺមានតែរដ្ឋទេដែលមាននិរន្តរភាព។ មូលហេតុដែលរដ្ឋពុំមាននិរន្តរភាពនោះក៏ព្រោះ តែរដ្ឋាភិបាលអាចនឹងត្រូវបានផ្លាស់ប្តូរទៅតាមការចង់បានរបស់ប្រជាពលរដ្ឋ ឬ អាចត្រូវបានរៀបចំឡើងតាមមធ្យោបាយផ្សេង។

# ផ្នែកទី៤ ដែនដីរដ្ឋ

- សញ្ញាណទូទៅ

ប្រសិនបើមានប្រជាជន និងរដ្ឋាភិបាលហើយ មិនទាន់គ្រប់គ្រាន់នោះឡើយទេ គឺត្រូវតែមានដែនដីជាកំណត់ជាក់លាក់របស់ខ្លួនពិតប្រាកដ ទើបអាចធ្វើឲ្យរដ្ឋនោះមានអត្ថិភាពទៅបាន។

# ផ្នែកទី៤ ដែនដីរដ្ឋ

- សញ្ញាណទូទៅ

ដែនដីរបស់រដ្ឋ គឺជាទីតាំងដែលយកមកធ្វើជាមូលដ្ឋាននៃរដ្ឋណាមួយ ដែលជាធាតុផ្សំយ៉ាងសំខាន់មិនអាចខ្វះបាន។ ដូចទៅនឹងចំនួនប្រជាពលរដ្ឋដែល ដែនដីរដ្ឋពុំមានការកំណត់ថាត្រូវមានទំហំប៉ុណ្ណានោះឡើយ។

# ផ្នែកទី៤ ដែនដីរដ្ឋ

- សញ្ញាណទូទៅ

ទោះបីជាមានបញ្ហាព្រំដែន ឬ ទំនាស់ទឹកដី (ការមានទំនាស់ក្នុងការកំណត់ខ្សែបន្ទាត់ព្រំដែន) ដែលនាំឲ្យមានប៉ះពាល់ដល់បូរណភាពទឹកដីក៏ដោយ ក៏មិនជះឥទ្ធិផលដល់អត្ថិភាពនៃរដ្ឋនោះទេ។

# ផ្នែកទី៤ ដែនដីរដ្ឋ

- សមាសភាពដែនដី

ដែនដីរបស់រដ្ឋ មានសមាសភាពចំនួនបី គឺដែនដីគោក ដែនសមុទ្រ ឬ អាចហៅបានថាដែនទឹក និងដែនអាកាស។ រដ្ឋទាំងឡាយមិនមែនសុទ្ធតែ មានសមាសភាពដែនដីទាំងបីនេះទេ គឺមានរដ្ឋមួយចំនួនមានតែសមាសភាពដែនដីគោក និងដែអាកាសតែប៉ុណ្ណោះ។

# ផ្នែកទី៤ ដែនដីរដ្ឋ

- សមាសភាពដែនដី

ដែនដីគោក: គឺជាដីគោកដែលហ៊ុំព័ទ្ធដោយព្រំដែនគោក និងព្រំដែនទឹក។ ដូចបានបញ្ជាក់ពីខាងលើ រដ្ឋមួយចំនួនពុំមានព្រំដែនទឹកនោះទេ ដែលគេហៅថារដ្ឋគ្មានដែនទឹក ឬ ដែនសមុទ្រ (LANDLOCKED COUNTRY)។ ប្រទេសដែលគ្មានព្រំដែនទឹកមានចំនួន ១១,៤ ភាគរយ នៃផ្ទៃដីរបស់ពិភពលោក។

# ផ្នែកទី៤ ដែនដីរដ្ឋ

- សមាសភាពដែនដី

ដែនទាំងបីនៃសមាសភាពដែនដីរដ្ឋ ការកំណត់ព្រំដែននៃដែនដីរបស់រដ្ឋ យើងនឹងនៅសិក្សាលម្អិតនៅក្នុងមេរៀនទី៩ ស្តីពី រដ្ឋ (ដែនដីនៃរដ្ឋ)។

មេរៀនទី៨ ស្តីពីរដ្ឋ (ធាតុផ្សំនៃរដ្ឋ) ត្រូវបានបញ្ចប់។ សូមអរគុណ សម្រាប់ការតាមដានដោយយកចិត្តទុកដាក់ពីសំណាក់អ្នកសិក្សាទាំងឡាយ។